# **ដំណឹងជ្រើសរើសបុគ្គលិក**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **សីលានិធិ លីមីធីត** ទទួលបានអាជ្ញាប័ណ្ណអចិន្ត្រៃពីធនាគារជាតិនៃកម្ពុជា កំពុងបម្រើសេវាកម្ម មីក្រូហិរញ្ញវត្ថុនៅក្នុង ២៥សាខា ខេត្ត -ក្រុង-ស្រុក នៅក្នុងរាជធា នីភ្នំពេញ ខេត្តកណ្តាល ខេត្តពោ ធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងខេត្តកំពង់ចាម។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **សីលានិធិ លីមីធីត** ត្រូវការជ្រើសរើស**បុគ្គលិកជំនួយការការិយាល័យ**( **សន្តិសុខ** )១រូបសម្រាប់បំរើការងារនៅ **សាខាខេត្តបាត់ដំបង។**

១. ***ភារកិច្ច និងការទទួលខុសត្រូវ:***

បុគ្គលិកសន្តិសុខ ត្រូវទទួលខុសត្រូវក្នុងការយាមកាមប្រចាំការនៅក្នុងសាខាដែលមានភារៈកិច្ច និងការទទួលខុសត្រូវខាងក្រោមៈ

១. ថែរក្សាសុវត្ថិភាពនៅក្នុងសាខាឲ្យបានល្អនិងថែរក្សាទ្រព្យសម្បត្តិទាំងអស់របស់សាខាឲ្យបានគង់វង្ស។
២. ថែរក្សាអនាម័យ នៅក្នុងសាខា និងសម្ភារៈ បរិក្ខារប្រើប្រាស់ផ្សេងៗរបស់សាខាឲ្យមាន អនាម័យល្អ។
៣. កត់ត្រារាល់ព័ត៌មានរបស់ភ្ញៀវដែលចេញ និងចូលមកទំនាក់ទំនងជាមួយសីលានិធិ។
៤. ត្រួតពិនិត្យ និងថែទាំ ប្រព័ន្ធទឹក/ភ្លើង និងទូរសព្ទ។
៥. ជួសជុលសម្ភារៈប្រើប្រាស់របស់សាខា និងថតចម្លងឯកសារ។

២. ***លក្ខណៈសម្បត្តិដែលបេក្ខជនត្រូវមានៈ***

១. បេក្ខជនត្រូវជា ជនជាតិខ្មែរ។
២. បេក្ខជនត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ។
៣. បញ្ចប់ការសិក្សាត្រឹមថ្នាក់ទី១២ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
៤. ជាមនុស្ស ស្មោះត្រង់ និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងារ។
៥. មានសុខភាពល្អ និងកាយសម្បទាមាំមួន។
៦. មានអត្តសញ្ញាណប័ណ្ណច្បាស់លាស់ និង មិនធ្លាប់មានជាប់ពិរុទ្ធ។
៧. ជាមនុស្សម៉ឺងម៉ាត់ និងហ្មត់ចត់នៅក្នុងការងារ។

បេក្ខជនដែលមានចំណាប់អារម្មណ៍លើការងារនេះ សូមភ្ជាប់នូវរូបថតថ្មី 4 x 6 ចំនួន ៣សន្លឹក ប្រវត្តិរូបសង្ខេប១ច្បាប់ ថតចម្លងសៀវភៅគ្រួសារ អត្ត សញ្ញាណប័ណ្ណ និងឯកសារផ្សេងៗទៀ តមកកាន់ការិយាល័យកណ្តាល ផ្ទះលេខ ១SF ២SF ផ្លូវលេខ ៥១៦ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឬ គ្រប់ការិយាល័យ សាខាស្រុក ក្រុង ខេត្ត របស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សីលានិធិ។

ចាប់ទទួលពាក្យសុំបម្រើការងារ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ និងឈប់ទទួលពាក្យនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៤ វេលាម៉ោង ៥ ល្ងាច។